ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

សំណុំរឿងព្រហ្មទណ្ឌលេខ ១៧៥៩ អ.ក
ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២
សាលក្រមលេខ ០៥៣ ស.ព្រ.ណ/២៣
ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣

## តាមនាមប្រជារាស្ត្រខ្មែរ

បានបើកសវនាការជាអសាធារណៈ នៅសាលាដំបូងខេត្តកណ្ដាល ។
កាលបរិច្ឆេទសវនាការ ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២៣ ។
កាលបរិច្ឆេទនៃការប្រកាសសាលក្រមថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣ ។

### ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមជំនុំជម្រះ
លោក ចៅក្រមប្រឹក្សា
លោក ចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារង

### ក្រឡាបញ្ជី

លោក [redacted] ក្រឡាបញ្ជីសវនាការ

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ១៧៥៩ អ.ក ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ ដែលមានជនជាប់ចោទ៖

១. ឈ្មោះ [redacted]ថារ៉ូ ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរជាងសំណង់ ទីកន្លែងកំណើតភូមិ[redacted] ខេត្តកណ្ដាល និង ទីលំនៅមុនពេលឃាត់ខ្លួនភូមិលេខ២ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្ដាល ឪពុកឈ្មោះ រឿន (រ) ម្ដាយឈ្មោះ [redacted] ស្រីតូ (រ) ប្រពន្ធឈ្មោះ ខួច គ្មានកូន ទោសពីមុនគ្មាន ។ (ក្នុងឃុំ)

២. ឈ្មោះ [redacted] ធារិទ្ធ ហៅ ធី ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតភូ[redacted] ខេត្តកណ្ដាល និង ទីលំនៅមុនពេលឃាត់ខ្លួនភូមិលេខ២ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្ដាល ឪពុកឈ្មោះ[redacted]សុខរី (រ) ម្ដាយឈ្មោះ [redacted]រចនា (រ) នៅលីវ ទោសពីមុន គ្មាន ។ (ក្នុងឃុំ)

៣. ឈ្មោះ [redacted] បូរិន ហៅ ម៉ៅ ភេទប្រុស អាយុ ២៦ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរចុងភៅ ទីកន្លែងកំណើត និង ទីលំនៅមុនពេលឃាត់ខ្លួនភូមិ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] រ៉ក់ (រ) ម្តាយឈ្មោះ [redacted] ថន (រ) មានប្រពន្ធឈ្មោះ [redacted] តុសិកា (រ) មានកូន ១នាក់ ទោសពីមុន គ្មាន ។ (ក្នុងឃុំ)

៤. ឈ្មោះ [redacted] ស្រីតូ ភេទស្រី អាយុ ៣៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរលក់ដូរ ទីកន្លែងកំណើតភូមិ [redacted] ខេត្តកណ្តាល និង ទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្តាល មានប្តីឈ្មោះ រឿន (ស) មានកូន ៥នាក់ ទោសពីមុន គ្មាន ។ (ក្នុងឃុំ)

ត្រូវបានជាប់ចោទពី **បទរក្សាទុក និង ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចភូមិលេខ៣ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសស្របតាមបញ្ញត្តិមាត្រា មាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

មានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ថារ៉ូ ភេទប្រុស អាយុ ១៧ឆ្នាំ និង ឈ្មោះ [redacted] ធារិទ្ធ ភេទប្រុស អាយុ ១៧ឆ្នាំ ។

- **បានឃើញ** ដីកាដំណោះស្រាយលេខ ២០៩ ចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២៣ ។

## អង្គហេតុដែលបានចោទប្រកាន់បញ្ជូនមកជំនុំជម្រះ

កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ វេលាម៉ោង ២១ និង ០៥នាទី កម្លាំងជំនាញប៉ុស្តិ៍នគរបាលរដ្ឋបាលស្វាយរលំ បានចេញល្បាតតាមភូមិសាស្ត្រនៅចំណុចភូមិលេខ ៣ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្តាល ក៏បានចុះទៅដល់បន្ទប់ជួលរបស់ឈ្មោះ [redacted] បូរិន ដោយមានការសង្ស័យបានសួរនាំ និង បានឆែកឆេររកឃើញម្សៅក្រាមសថ្លា ជាសារធាតុញៀនចំនួន ៥កញ្ចប់តូច ហើយក៏បានធ្វើការឃាត់ខ្លួនតែម្តង ។ នៅចំពោះមុខជនត្រូវចោទឈ្មោះ [redacted] បូរិន បានសារភាពថា ថ្នាំញៀនទាំង ០៥កញ្ចប់តូចនេះជារបស់ខ្លួនពិតមែនដែលបានទិញពីឈ្មោះ តូ ក្នុងតម្លៃ ៥០.០០០ រៀល ។ សមត្ថកិច្ចបានស្វែងរកឈ្មោះ តូ បន្តទៅដល់ផ្ទះ ហើយក៏បានរកឃើញជនត្រូវចោទឈ្មោះ [redacted] ថារ៉ូ និង ឈ្មោ [redacted] ធារិទ្ធ កំពុងនៅទីនោះ ភ្លាមនោះសមត្ថកិច្ចក៏បានឆែកឆេររកឃើញម្សៅក្រាមសថ្លា ចំនួន ១០កញ្ចប់នោះ ជារបស់ឈ្មោះ [redacted] ថារ៉ូ បានផ្ញើទុកនៅខ្លួនសម្រាប់លក់ ។ តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ថារ៉ូ បានសារភាពថា ថ្នាំញៀនចំនួន ១០ កញ្ចប់នោះ ខ្លួនបានទិញពីម្តាយរបស់ខ្លួន ឈ្មោះ [redacted] ស្រីតូ រួចយកទៅឱ្យឈ្មោះ [redacted] ធារិទ្ធ ដើម្បីទុកលក់បន្តពិតប្រាកដមែន ។



Scanned with CamScanner

## ដំណើរការនៃកិច្ចពិភាក្សាដេញដោល

១. ជនជាប់ចោទឈ្មោះ [redacted] ថារ៉ូ ឆ្លើយថា ៖ ខ្ញុំទទួលស្គាល់អង្គហេតុខាងលើ ។ ថ្នាំញៀនខ្ញុំបានទិញពីម្ដាយបង្កើត ដែលឈ្មោះ [redacted] ស្រីគួ តម្លៃ ៥០.០០០ រៀល ដើម្បីទុកលក់បន្ត ។ ខ្ញុំបានផ្ញើថ្នាំញៀន ១០កញ្ចប់នៅឈ្មោះ [redacted] ធារិទ្ធ ។

២. ជនជាប់ចោទឈ្មោះ [redacted] ធារិទ្ធ ឆ្លើយថា ៖ ខ្ញុំមិនដែលលក់ថ្នាំញៀនទេ ថ្នាំញៀន ១០កញ្ចប់ ជារបស់ឈ្មោះ [redacted] ថារ៉ូ ដែលផ្ញើទុកនឹងខ្ញុំ ។

៣. ជនជាប់ចោទឈ្មោះ [redacted] បូរិន ឆ្លើយថា ៖ ថ្នាំញៀន ៥កញ្ចប់របស់ខ្ញុំទិញពីឈ្មោះ គួ ម្ដាយរបស់ឈ្មោះ [redacted] ថារ៉ូ ទុកសម្រាប់ប្រើប្រាស់ ។

៣. តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំថា៖ តំណាងអយ្យការ នៅតែរក្សាការចោទប្រកាន់ និង ប្ដឹងសុំឱ្យតុលាការសម្រេចផ្ដន្ទាទោសជនជាប់ចោទ ដោយមានភស្តុតាងស៊ីសង្វាក់គ្នា ។

៥. មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ថារ៉ូ និង ឈ្មោះ [redacted] ធារិទ្ធ ធ្វើសេចក្ដីសន្និដ្ឋានថា ៖ ស្នើសុំតុលាការផ្ដល់ស្ថានសម្រាល មូលហេតុជនជាប់ចោទជាអនីតិជន ។

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ
-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ
-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
-ក្រោយពីបានស្ដាប់សម្ដីចុងក្រោយរបស់ជនជាប់ចោទ
-ក្រោយពីបានពិនិត្យភស្តុតាងលើសំណុំរឿងនេះ

## សំអាងហេតុ

១. យោងតាមចម្លើយរបស់ជនជាប់ចោទ និង ភស្តុតាងនានា អាចបញ្ជាក់បានថានៅថ្ងៃកើតហេតុសមត្ថកិច្ចបានធ្វើការឆែកឆេរលើជនជាប់ចោទឈ្មោះ [redacted] បូរិន រកឃើញម្សៅក្រាមសថ្លា ចំនួន ៥កញ្ចប់ ដែលបានទិញពីឈ្មោះ [redacted] ស្រីគួ និង បានធ្វើការឃាត់ខ្លួនជនជាប់ចោទតែម្ដង រួចបន្តទៅរកឈ្មោះ [redacted] ស្រីគួ បានជួបឈ្មោះ [redacted] ថារ៉ូ និង ឈ្មោះ [redacted] ធារិទ្ធ រកឃើញថ្នាំញៀនម្សៅក្រាមសថ្លាចំនួន ១០កញ្ចប់ លើខ្លួនឈ្មោះ [redacted] ធារិទ្ធ ដែលឈ្មោះ [redacted] ថារ៉ូ ផ្ញើទុកឱ្យលក់ ។ ហើយជនជាប់ចោទឈ្មោះ [redacted] ថារ៉ូ ក៏បានឆ្លើយថា ថ្នាំញៀនចំនួន ១០កញ្ចប់ នោះខ្លួនបានទិញពីម្ដាយបង្កើតឈ្មោះ [redacted] ស្រីគួ ទុកឱ្យឈ្មោះ [redacted] ធារិទ្ធិ លក់បន្ត ។ ដូចនេះតុលាការយល់ឃើញថាឈ្មោះ [redacted] បូរិន បានរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ឈ្មោះ [redacted] ថារ៉ូ និង ឈ្មោះ [redacted] ធារិទ្ធ បានរក្សាទុក និង ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និង ឈ្មោះ [redacted] ស្រីគួ ភេទស្រី



Scanned with CamScanner

អាយុ ៣៨ឆ្នាំ បានជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដោយមានចម្លើយ និង ភស្តុតាងស៊ីសង្វាក់គ្នា ។ (ថ្នាំញៀនប្រភេទម្សៅក្រាមសថ្លា សរុបទម្ងន់ ១,៧៥ ក្រាម ជាសារធាតុមេតំហ្វេតាមីន) ។

២. ជនជាប់ចោទខាងលើ ជានីតិជន និង មានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ ។

៣. ជនជាប់ចោទខាងលើដឹងថាអំពើរបស់ខ្លួនផ្ទុយនឹងច្បាប់ ប៉ុន្តែនៅតែប្រព្រឹត្តផ្ទុយច្បាប់ទៀត ។ ដូចនេះតុលាការយល់ឃើញថា ជនជាប់ចោទមានចេតនាក្នុងការប្រព្រឹត្តបទល្មើស ។

៤. តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា សុំរក្សាការចោទប្រកាន់លើជនជាប់ចោទដដែល និងប្ដឹងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទ ដោយតាមភស្តុតាងមានភាពស៊ីសង្វាក់គ្នា ។ តុលាការនឹងពិចារណាសម្រេច ស្របតាមអង្គហេតុ និង អង្គច្បាប់ ។

៥. បន្ទាប់ពីឆ្លងកាត់ការពិភាក្សាដេញដោល និង ការពិនិត្យនូវភស្តុតាងនានាក្នុងសំណុំរឿង អាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] បូរិន បានប្រព្រឹត្ត **បទរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសស្របតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី១ និង កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឈ្មោះ [redacted] ថារ៉ូ ឈ្មោះ [redacted] ធារិទ្ធ បានប្រព្រឹត្ត **បទរក្សាទុក និង ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសស្របតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី១ កថាខណ្ឌទី៣ និង កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និង ឈ្មោះ [redacted] ស្រីតូ បានប្រព្រឹត្ត **បទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសស្របតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិលេខ៣ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ ។

៦. ជនជាប់ចោទឈ្មោះ [redacted] ស្រីតូ បានរត់គេចខ្លួន និង អវត្តមានគ្រប់នីតិវិធី ។ ដូចនេះតុលាការនឹងសម្រេចអំពីការចាប់ខ្លួន ស្របតាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## ហេតុដូច្នេះសម្រេច

១. ឱ្យជនជាប់ចោទឈ្មោះ [redacted] បូរិន ភេទប្រុស អាយុ ២៦ឆ្នាំ ដែលមានអត្តសញ្ញាណដូចខាងលើ រួចខ្លួនពី **បទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិលេខ៣ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសស្របតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២. ឱ្យជនជាប់ចោទឈ្មោះ [redacted] ស្រីតូ ភេទស្រី អាយុ ៣៨ឆ្នាំ ដែលមានអត្តសញ្ញាណដូចខាងលើ រួច



Scanned with CamScanner

ខ្លួនពី **បទរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិ លេខ៣ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្ដន្ទាទោសស្របតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣. ផ្ដន្ទាទោស

ក. ឈ្មោះ [redacted] ថារ៉ូ ភេទប្រុស អាយុ ១៧ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០១ (មួយ) ឆ្នាំ ០៦ (ប្រាំមួយ) ខែ

ខ. ឈ្មោះ [redacted] **ធារិទ្ធ** ភេទប្រុស អាយុ ១៧ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០១ (មួយ) ឆ្នាំ ០៦ (ប្រាំមួយ) ខែ

ពី **បទរក្សាទុក និង ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិលេខ៣ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្ដន្ទាទោសស្របតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី១ កថាខណ្ឌទី៣ និង កថាខណ្ឌទី៤ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

៤. ផ្ដន្ទាទោសឈ្មោះ [redacted] បូរិន ភេទប្រុស អាយុ ២៦ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០២ (ពីរ) ឆ្នាំ ០៦ (ប្រាំមួយ) ខែ ពី **បទរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិលេខ៣ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្ដន្ទាទោសស្របតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី១ និង កថាខណ្ឌទី៤ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

៥. ផ្ដន្ទាទោសឈ្មោះ [redacted] ស្រីតូ ភេទប្រុស អាយុ ២៦ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០៣ (បី) ឆ្នាំ និង ពិន័យជាប្រាក់ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ពី **បទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិលេខ៣ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្ដន្ទាទោសស្របតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៣ និង កថាខណ្ឌទី៤ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

៦. បង្គាប់ឱ្យចាប់ និង ឃុំខ្លួន ឈ្មោះ [redacted] ស្រីតូ ភេទស្រី អាយុ ៣៨ឆ្នាំ ដែលមានអត្តសញ្ញាណដូចខាងលើ ។

៧. រឹបអូសវត្ថុចាប់យករួមមាន ម្សៅក្រាមពណ៌សថ្លា ចំនួន ១៥កញ្ចប់ (ទម្ងន់ ១,៧៥ក្រាម) និង ឧបករណ៍វេចខ្ចប់មួយចំនួន ។



Scanned with CamScanner

សាលក្រមនេះ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted] ចារ៉ូ ឈ្មោះ[redacted] បូរិន ឈ្មោះ[redacted]ធារិទ្ធ និង កំបាំងមុខជនជាប់ចោទឈ្មោះ[redacted] ស្រីតូ ។ ទុកសិទ្ធិប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍ តាមនីតិវិធីច្បាប់ ។

ថ្ងៃពុធ ១៤រោច ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៦

កណ្តាល, ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
| --- | --- | --- | --- |
| ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |

[redacted]

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ១៤រោច ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៦

កណ្តាល, ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]